*Embassy of Japan*

ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤

សម្តេច ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រជាជនកម្ពុជាទាំងអស់ជាទីគោរពរាប់អានដ៏ខ្ពង់ខ្ពស់។

ទូលព្រះបង្គំជាខ្ញុំ **គូម៉ាម៉ារូ យូជិ** ជាឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា។ ជាបឋម ទូលព្រះបង្គំជាខ្ញុំ សូមថ្លែងអំណរព្រះគុណនិងអរគុណប្រកបដោយក្តីសោមនស្សរីករាយចំពោះ សម្តេច ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រជាជនកម្ពុជាទាំងអស់ដែលតែងតែជឿទុកចិត្តនិងគាំទ្ររាល់សកម្មភាពរួមចំណែករបស់ប្រទេសជប៉ុន នៅក្នុងទឹកដីប្រទេសកម្ពុជាកន្លងមកនេះ។

ប្រាង្គប្រាសាទអង្គររបស់ប្រទេសកម្ពុជាដែលជាមោទនភាពដ៏វិសេសវិសាលរបស់ពិភពលោក កំពុងតែបានក្លាយជាគោលដៅតំបន់ទេសចរណ៍លំដាប់ថ្នាក់ពិភពលោក ដែលបាននិងកំពុងតែទាក់ទាញភ្ញៀវទេសចរណ៍ឱ្យមកចូលទស្សនាមានចំនួនជាង២លាននាក់ក្នុងមួយឆ្នាំៗ។ ដោយឡែក កាលពីឆ្នាំ១៩៩២ដែលពេលនោះប្រាង្គប្រាសាទអង្គរទើបតែត្រូវបានចុះបញ្ជីជាសម្បត្តិបេតិកភណ្ឌពិភពលោករបស់អង្គការ UNESCO ប្រាសាទអង្គរត្រូវបានចាត់ទុកជាបេតិកភណ្ឌពិភពលោកស្ថិតក្នុងសភាពគ្រោះថ្នាក់ (World Heritage in Danger) ដែលពេលនោះគឺជាស្ថានភាពមួយដ៏គ្រោះថ្នាក់និងគួរឱ្យព្រួយបារម្ភ សំរាប់ការបន្តមានវត្តមានរបស់ប្រាង្គប្រាសាទមួយនេះហើយដែលព្រឹត្តិការណ៍នេះមិនសូវបានជ្រាបពីសំណាក់ប្រជាជនភាគច្រើននោះទេ។

ប្រទេសជប៉ុនបាននិងកំពុងតែអនុវត្តសកម្មភាពស្តារឡើងវិញ និងអភិរក្សប្រាង្គប្រាសាទអង្គរអស់រយៈពេលជាង២០ឆ្នាំមកហើយ។ នៅពេលនេះ ទូលព្រះបង្គំជាខ្ញុំ សូមអនុញ្ញាត្តិទូលថ្វាយនិងជំរាបជូនពីសកម្មភាពទាំងនោះរបស់ប្រទេសជប៉ុន។

នៅឆ្នាំ១៩៩៣ ប្រទេសជប៉ុនបានរៀបចំសន្និសីទដ៏ធំមួយនៅទីក្រុងតូក្យូដែលមានឈ្មោះថា "សន្និសីទអន្តររដ្ឋាភិបាលស្តីអំពីកិច្ចគាំពារនិងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរលើកទី១" ។ តាមរយៈសន្និសីទមួយនេះដែលមានប្រទេសជប៉ុននិងប្រទេសបារាំងជាសហប្រធាននោះ គណៈកម្មាធិការអន្តរជាតិដើម្បីសម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ (ICC) ត្រូវបានបង្កើតឡើង។ ចាប់តាំងពីពេលនោះមក កិច្ចប្រជុំគណៈកម្មាធិការ ICC បានដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលកម្មវិធីអភិរក្សនិងអភិវឌ្ឍន៍ដោយបណ្តាប្រទេសនានាដែលជាដៃគូពាក់ព័ន្ធ ហើយប្រទេសជប៉ុននិងប្រទេសបារាំងបានដើរតួនាទីដ៏សំខាន់ជាសហប្រធានមកទល់នឹងបច្ចុប្បន្ននេះមានរយៈពេល២០ឆ្នាំហើយ។

ជាងនេះទៅទៀត នៅឆ្នាំ១៩៩៤រដ្ឋាភិបាលជប៉ុនបានបង្កើតក្រុមការងារសម្រាប់អភិរក្សអង្គរហៅកាត់ថា JSA ហើយចាប់តាំងពីពេលនោះមកដល់ឆ្នាំ២០១១ ប្រទេសជប៉ុនបានចំណាយថវិការប្រមាណជាង២៤លានដុល្លារសហ

*No.194, Moha Vithei Preah Norodom, Phnom Penh, Cambodia (P.O.BOX21, Phnom Penh)*
*Tel: 855 (23) 217 161~4, Fax: 855 (23) 216 162*

រដ្ឋអាមេរិកនៅក្នុងសកម្មភាពជួសជុលនិងស្តារឡើងវិញនូវប្រាង្គប្រាសាទអង្គរ និង ប្រាសាទបាយ័ន។ ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ប្រទេសជប៉ុនបានបញ្ជូនអ្នកជំនាញការជប៉ុនចំនួន១១០០នាក់មកកាន់ប្រទេសកម្ពុជា និងបានបង្ហាត់បង្រៀនសឈាមយ៉ាងស្វាហាប់ នៅក្នុងសកម្មភាពជួសជុលនិងស្តារឡើងវិញប្រាង្គប្រាសាទនានាជាមួយនិងបុគ្គលិកកម្ពុជា។ សកម្មភាពទាំងនេះនៅតែបន្តរហូតមកដល់សព្វថ្ងៃ ហើយចាប់ពីឆ្នាំ២០១២ទៅ គំរោងទី៤ដែលមានរយៈពេល៥ឆ្នាំកំពុងតែត្រូវបានបន្តអនុវត្តដែលគំរោងនេះ នឹងត្រូវចំណាយថវិការសរុបប្រមាណ២.៥លានដុល្លារសហរដ្ឋអាមេរិក។

ជាងនេះទៅទៀត ដើម្បីឧបត្ថម្ភដល់ការផ្គត់ផ្គង់សម្ភារៈចាំបាច់ក្នុងដំណើរការកែលំអជួសជុលស្ពានហាលខាងលិចនៃប្រាសាទអង្គរវត្ត រដ្ឋាភិបាលជប៉ុនបានផ្តល់ជំនួយឥតសំណងសំរាប់គម្រោងសហប្រតិបត្តិការវប្បធម៌ដែលមានទឹកប្រាក់សរុបប្រមាណ១លានដុល្លារសហរដ្ឋអាមេរិក។ ក្រោមកិច្ចសហប្រតិបត្តិការរបស់សាកលវិទ្យាល័យសូហ្វីយ៉ាប្រទេសជប៉ុននៅក្នុងសកម្មភាពជួសជុលស្ពានហាលខាងលិចប្រាសាទអង្គរវត្ត បានផ្តល់ឱកាសដល់រាជរដ្ឋាភិបាលកម្ពុជានិងប្រជាជនកម្ពុជា ដើម្បីអនុវត្តសកម្មភាពជួសជុលនិងស្តារឡើងវិញនូវគំរោងទាំងនោះដោយផ្ទាល់ដៃរបស់ខ្លួន។ តាមរយៈសកម្មភាពជួសជុលមួយនេះ យើងនឹងពាំនាំមកវិញនូវសម្រស់ដ៏ប្រណិតនៃស្ពានហាលខាងលិចដែលជាច្រកចូលធំចម្បងរបស់ប្រាសាទអង្គរវត្ត និងអាចរក្សាបាននូវសុវត្ថិភាពនិងផាសុកភាពសំរាប់ភ្ញៀវទេសចរណ៍ទាំងអស់ដែលអញ្ជើញមកទស្សនាប្រាសាទអង្គរវត្ត។

ក្រៅពីនេះ ស្ថាប័នអប់រំនិងស្រាវជ្រាវមួយចំនួននៅប្រទេសជប៉ុនមានដូចជា វិទ្យាស្ថានស្រាវជ្រាវសម្បត្តិវប្បធម៌ណារ៉ា វិទ្យាស្ថានស្រាវជ្រាវសម្បត្តិវប្បធម៌តូក្យូ និងសាកលវិទ្យាល័យកាណាហ្សាវ៉ាជាដើម ក៏បានលើកកម្ពស់ការរួមចំណែករបស់ប្រទេសជប៉ុន តាមរយៈការរួមចំណែកក្នុងកិច្ចការស្តារឡើងវិញនិងអភិរក្សប្រាង្គប្រាសាទអង្គរនៅប្រទេសកម្ពុជាផងដែរ។

ក្នុងនាមជាឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា ទូលព្រះបង្គំជាខ្ញុំ ពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដែលរដ្ឋាភិបាលជប៉ុនបាននិងកំពុងផ្តល់នូវជំនួយជាច្រើនសណ្ឋានដើម្បីស្តារឡើងវិញនិងអភិរក្សអ្វីដែលជា "មោទនភាពរបស់កម្ពុជា" ។ ទូលព្រះបង្គំជាខ្ញុំ មានក្តីរំពឹងយ៉ាងមុតមាំថា ជំនួយនិងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរនៅក្នុងវិស័យមួយនេះក៏ដូចជាវិស័យដទៃជាច្រើនទៀតនឹងកាន់តែមានភាពសកម្មជាផ្លែផ្កាបន្ថែមទៀតទៅថ្ងៃអនាគត។

ជាចុងក្រោយនេះ ទូលព្រះបង្គំជាខ្ញុំ សូមអនុញ្ញាតថ្វាយនិងជូននូវសព្ទសាធុការពរបវរមហាប្រសើរ សូមសម្តេច ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រជាជនកម្ពុជាទាំងអស់ប្រកបដោយសុខភាពល្អបរិបូរណ៍ និង ជោគជ័យគ្រប់ភារៈកិច្ច។

**គូម៉ាម៉ារូ យូជិ**

**ឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាពជប៉ុន**

**ប្រចាំព្រះរាជាណាចក្រកម្ពុជា**